**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ ៦៩.អនក្រ.បក

## អនុក្រឹត្យ
## ស្តីពី
## ការប្រើប្រាស់គណនីឯកជនតាខុបនីយកម្មសហគ្រាសសាធារណៈ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស /រកត /០៩០៨ /១០៥៥ .ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ នស / ៩៤ .ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស /រកម / ០៥០៨/ ០១៦ .ចុះថ្ងៃទី ១៣ ខែ ឧសភា ឆ្នាំ ២០០៨ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រឹត្យលេខ ១១នស៩៤.ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ១៩៩៤ ប្រកាសឲ្យប្រើច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ១៩៩៥
- បានឃើញព្រះរាជក្រមលេខ នស /រកម / ១២១០/ ០១៧ .ចុះថ្ងៃទី ២២ ខែ ធ្នូ ឆ្នាំ ២០១០ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីហិរញ្ញវត្ថុ សម្រាប់ការគ្រប់គ្រង ឆ្នាំ ២០១១
- បានឃើញព្រះរាជក្រមលេខជស/រកម/០១៩៨/០១.ចុះថ្ងៃទី៣១ខែធ្នូ ឆ្នាំ១៩៩៨ប្រកាសឲ្យប្រើច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ១៩៩៨
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក .ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៨១ អនក្រ.បក.ចុះថ្ងៃទី ១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥ ស្តីពីការបង្កើតការត្រួតពិនិត្យហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ៨២អនក្រ.បក.ចុះថ្ងៃទី១៦ខែវិច្ឆិកាឆ្នាំ១៩៩៥ស្តីពីបទបញ្ជាទូទៅនៃគណនេយ្យហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ៣៨ អនក្រ.បក.ចុះថ្ងៃទី ១៩ ខែ មេសា ឆ្នាំ ១៩៩៥ ស្តីពីបែបបទនៃឯកជនភាវូបនីយកម្មសហគ្រាសសាធារណៈ
- តាមសំណើរបស់រដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

## សម្រេច

**មាត្រា១** : អនុញ្ញាតឲ្យក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ប្រើប្រាស់គណនី " ឯកជនភាវូបនីយកម្មសហគ្រាសសាធារណៈ " ដែលត្រូវបានបង្កើតឡើងតាមមាត្រា៨៣ នៃច្បាប់ហិរញ្ញវត្ថុ សម្រាប់ការគ្រប់គ្រង ឆ្នាំ១៩៩៥មានទឹកប្រាក់ចំនួន ៥.០៨០.៣៦០ដុល្លារអាមេរិក (ប្រាំលានប៉ែតសិបពាន់បីរយហុកសិបដុល្លារអាមេរិកគត់) សម្រាប់ដំណើរការដោះស្រាយផលប៉ះពាល់សង្គមចំពោះក្រុមហ៊ុនចំការកៅស៊ូទាំង៧ចូលក្នុងគណនីរបស់គណៈកម្មាធិការជាតិអភិវិនិយោគនៅធនាគារជាតិនៃកម្ពុជា។

**មាត្រា២** . រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្រសួង ស្ថាប័នពាក់ព័ន្ធ មានភារកិច្ចអនុវត្ត អនុក្រឹត្យនេះឲ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ២៨ ខែ មេសា ឆ្នាំ ២០១១

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**បានយកសេចក្តីជម្រាបជូន**
**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**
**នាយករដ្ឋមន្ត្រី ដើម្បីចុះហត្ថលេខា**

**គាត ឈន់**
**រដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**កន្លែងទទួល**

ក្រសួងព្រះបរមរាជវាំង
អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
អគ្គលេខាធិការដ្ឋានរដ្ឋសភា
ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី
ឯកសារ-កាលប្បវត្តិ